# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ៤ មីនា ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 04-Mar-2013, 13:59
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំបើកកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៩៣ អំពីទីកន្លែងស្នាក់នៅរបស់សាក្សីសក្ដានុពល [redacted] (កោសលុប)**

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្តី អៀង សារី**

អាង ឧត្តម

Michael G. KARNAVAS

**ចម្លងជូន:**

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម **និល ណុន**

ចៅក្រម **យូរ ឧត្តរា**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង **ធួ មុន្នី**

ចៅក្រមបម្រុង Claudia FENZ

**ចម្លងជូន:**

**សហព្រះរាជអាជ្ញា:**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) លោក អៀង សារី សូមឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា (“ក.ស.ព”) សុំបើកកិច្ចស៊ើបសួរស្របតាមវិធាន ៩៣ អំពីទីកន្លែងស្នាក់នៅរបស់សាក្សីសក្តានុពល [redacted] (“សំណើ”)[1]។ ចម្លើយតបនេះមានភាពចាំបាច់ដោយហេតុថា៖ **ក.** សំណើសុំបំពេញកិច្ចស៊ើបសួរគឺជាសំណើពុំទាន់ពេលវេលា និងគួរត្រូវបានធ្វើនៅដំណាក់កាលមុនការជំនុំជម្រះ និង **ខ.** ការលើកឡើងរបស់ ក.ស.ព ដែលថាប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់ [redacted] ជាមួយសាស្ត្រាចារ្យ Benedict Kiernan អាចត្រូវបានទទួលយកជាភស្តុតាងប្រសិនបើ [redacted] ស្លាប់ ឬពុំអាចត្រូវបានស្វែងរកឃើញដោយការខិតខំយ៉ាងសមស្រប ត្រូវតែគ្មានសុពលភាពដោយអនុលោមវិធាន ៨៧ នៃវិធានផ្ទៃក្នុង (“វិធាន”)។ មេធាវីការពារក្តីពុំជំទាស់ទៅនឹងខ្លឹមសារនៃសំណើរបស់ ក.ស.ព សុំបើកកិច្ចស៊ើបសួរ ស្របតាមវិធាន៩៣ អំពីទីកន្លែងស្នាក់នៅរបស់ [redacted] ឬភាពពាក់ព័ន្ធនៃភស្តុតាងរបស់ [redacted] ទៅនឹង ខៀវ សំផន ឡើយ។ មេធាវីការពារក្តីធ្វើសេចក្តីសន្និដ្ឋានតែទៅលើភាពអាចទទួលយកបាននៃប្រតិចារឹករបស់សាស្ត្រាចារ្យ Kiernan ជំនួសឱ្យសក្ខីកម្មនៅក្នុងតុលាការប៉ុណ្ណោះ ដោយហេតុថា ការទទួលយកឯកសារនេះគឺជាបញ្ហាមួយដែលអាចប៉ះពាល់ដល់លោក អៀង សារី (និងភាគីផ្សេងៗ) នៅថ្ងៃខាងមុខពាក់ព័ន្ធនឹងសាក្សីផ្សេងៗ។ មេធាវីការពារក្តីសូមដាក់បញ្ចូលជាឯកសារយោងនូវទឡ្ហីករណ៍ពាក់ព័ន្ធមុនៗទាំងអស់ដែលត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[2]។

## I. សាវតារ

1. កាលពីថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៩ ការិយាល័យសហចៅក្រមស៊ើបអង្កេត (“ក.ស.ច.ស”) បានសរសេរលិខិតទៅសាស្ត្រាចារ្យ Kiernan។ ក.ស.ច.ស បានស្នើសុំព័ត៌មាន អំពីការសម្ភាសន៍ដែល

[1] សំណើរបស់សហព្រះរាជអាជ្ញាសុំបើកកិច្ចស៊ើបសួរស្របតាមវិធាន ៩៣ អំពីទីកន្លែងស្នាក់នៅរបស់សាក្សីសក្តានុពល [redacted] ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣, ឯកសារ E266។

[2] *សូមមើល* ចម្លើយតបរបស់លោក អៀង សារី ចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងសំណើសុំឱ្យបើកសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារ E96/3។

សាស្ត្រាចារ្យ Kiernan បានធ្វើ និងបានលើកឡើងនៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា *របប ប៉ុល ពត (The Pol Pot Regime)*[3] *ក្នុងចំណោមព័ត៌មានផ្សេងៗ* ។

2. កាលពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ក.ស.ច.ស បានដាក់នៅក្នុងសំណុំរឿងនូវប្រតិចារឹកសរសេរដោយដៃនៃកិច្ចសម្ភាសន៍របស់សាស្ត្រារ្យ Kiernan ជាមួយ [redacted] និងបុគ្គលផ្សេងៗ[4]។ ប្រតិចារឹកនេះត្រូវបានបង្កើតឡើងដោយសាស្ត្រាចារ្យ Kiernan[5]។

3. កាលពីថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១០ សាស្ត្រាចារ្យ Kiernan បានជូនដំណឹងទៅ ក.ស.ច.ស ថាគាត់បានធ្វើកិច្ចសម្ភាសន៍មួយជាមួយ [redacted] ហើយកិច្ចសម្ភាសន៍នោះត្រូវបានថតខ្សែអាត់។ សាស្ត្រាចារ្យ Kiernan បានគូសបញ្ជាក់ថាគាត់ពុំមានខ្សែអាត់នេះទេ។ សាស្ត្រាចារ្យ Kiernan បានរំឭកថាសាស្ត្រាចារ្យ Michael Vickery បានមានវត្តមាននៅឯកិច្ចសម្ភាសន៍នេះ និងបានថតខ្សែអាត់នៃកិច្ចសម្ភាសន៍នេះ[6]។

4. កាលពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០ ក.ស.ច.ស បានសរសេរលិខិតទៅសាស្ត្រាចារ្យ Vickery។ ក.ស.ច.ស បានស្នើសុំឲ្យគាត់ប្រគល់មកឲ្យខ្លួននូវខ្សែអាត់នេះ និងព័ត៌មានបន្ថែមអំពីកិច្ចសម្ភាសន៍[7]។

5. កាលពីថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១០ សាស្ត្រាចារ្យ Vickery បានឆ្លើយតបថាគាត់ពុំបានចងចាំអំពីកិច្ចសម្ភាសន៍នេះទេ ប៉ុន្តែគាត់ប្រហែលជាបានមានវត្តមាននៅក្នុងកិច្ចសម្ភាសន៍នេះ។ គាត់បានគូសបញ្ជាក់ថាគាត់ពុំមានខ្សែអាត់នេះឡើយ[8]។

---

[3] លិខិតរបស់ ស.ច.ស ទៅ Ben Kiernan, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៩, ឯកសារ D269។ *សូមមើលផងដែរ* លិខិតរបស់ ស.ច.ស ទៅ Ben Kiernan ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១០, ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១០, ឯកសារ D269/3, ដោយបញ្ជាក់ជាថ្មីអំពីសំណើទៅសាស្ត្រាចារ្យ Kiernan ស្នើសុំព័ត៌មានអំពីកិច្ចសម្ភាសន៍ដែលគាត់បានធ្វើ។

[4] *សូមមើល* កិច្ចសម្ភាសន៍ជាមួយ [redacted], ឧត្តុង្គ, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៨១, ឯកសារ D313/1.2.405 ។

[5] ចម្លើយតបរបស់ Ben Kiernan ទៅ ស.ច.ស ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១០, ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០, ឯកសារ D269/4, កថាខណ្ឌ ៦។

[6] *ដូចឯកសារយោងខាងលើ* ។

[7] លិខិតរបស់ ស.ច.ស ទៅ Michael Vickery, ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០, ឯកសារ D269/8 ។

[8] សារអេឡិចត្រូនិករបស់ Michael Vickery ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១០, ឯកសារ D269/8/1.1។

6. កាលពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ក.ស.ព បានដាក់បញ្ជីឯកសារសម្រាប់សវនាការស្របតាមវិធាន៨០(៣)[9]។ ឧបសម្ព័ន្ធ ១២ នៃបញ្ជីនេះបានដាក់បញ្ចូលប្រតិចារឹកសរសេរដោយដៃរបស់សាស្ត្រាចារ្យ Kiernan នៃកិច្ចសម្ភាសន៍របស់គាត់ជាមួយ [redacted] និងបុគ្គលផ្សេងៗ[10]។

7. កាលពីថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ក.ស.ព បានដាក់បញ្ជីឯកសាររបស់ខ្លួន ដែលខ្លួនបានមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងការជំនុំជម្រះ នៅដំណាក់កាលទី១[11]។ ឧបសម្ព័ន្ធ ១២ នៃបញ្ជីនេះបានដាក់បញ្ចូលប្រតិចារឹកសរសេរដោយដៃរបស់សាស្ត្រាចារ្យ Kiernan នៃកិច្ចសម្ភាសន៍របស់គាត់ជាមួយ [redacted] និងបុគ្គលផ្សេងៗ[12]។

8. កាលពីថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ ក.ស.ព បានដាក់សំណើរបស់ខ្លួន។ ក.ស.ព បានលើកឡើងថាភស្តុតាងរបស់ [redacted] មានតម្លៃជាភស្តុតាងខ្ពស់ និងជួយដល់ការបញ្ជាក់ការពិត ដោយហេតុថាគាត់អាចផ្តល់ភស្តុតាងទាក់ទងនឹងផែនការរបស់មេដឹកនាំ ប.ក.ក ដើម្បីជម្លៀសប្រជាជនពីទីក្រុងភ្នំពេញតាំងពីឆ្នាំ ១៩៧៤[13]។ ក.ស.ព ក៏បានអះអាងថា [redacted] អាចផ្តល់ភស្តុតាងទាក់ទងនឹងការរួមចំណែកដែលត្រូវបានចោទប្រកាន់របស់ខៀវ សំផន និងការគាំទ្ររបស់ខៀវ សំផន ចំពោះផែនការទាំងនេះ[14]។ ក.ស.ព បានធ្វើការកត់សម្គាល់ថា ដោយអនុលោមតាមគោលការណ៍ភស្តុតាងដែលបានគូសបញ្ជាក់ដោយអង្គជំនុំជម្រះសាលាដំបូង ប្រសិនបើ [redacted] ពុំអាចទាក់ទងបានដើម្បីផ្តល់សក្ខីកម្មក្នុងនាមជាសាក្សី កិច្ចសម្ភាសន៍

---

[9] បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់សវនាការស្របតាមវិធាន ៨០(៣), ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១, ឯកសារ E9/31 ។

[10] បញ្ជីឯកសារសម្រាប់សវនាការរបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន ៨០(៣), ឧបសម្ព័ន្ធ ១២៖ ចម្លើយសាក្សី, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១, ឯកសារ E9/31.12, លេខ ៧៩៦។

[11] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ស្នើសុំឯកសារដែលទាក់ទិននឹងដំណាក់កាលដំបូងនៃការជំនុំជម្រះលើអង្គសេចក្តី, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារ E109/4។

[12] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ស្នើសុំឯកសារទាក់ទងនឹងការជំនុំជម្រះនៅដំណាក់កាលទីមួយ, ឧបសម្ព័ន្ធ១២៖ ចម្លើយសាក្សី, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារ E109/4.12 លេខ ៧៩៦។

[13] *សំណើ* កថាខណ្ឌ ៥,៧។

[14] *ដូចឯកសារយោងខាងលើ* ។

របស់គាត់ជាមួយសាស្ត្រាចារ្យ Kiernan នឹងអាចឲ្យទទួលយកបានជាភស្តុតាង[15]។ ក.ស.ព បានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង៖ **ក.** បង្គាប់ឲ្យមានកិច្ចស៊ើបសួរអំពីទីកន្លែងស្នាក់នៅរបស់ [redacted] **ខ.** ប្រសិនបើតុលាការរកឃើញ [redacted] តុលាការគួរកោះហៅឲ្យគាត់ចូលខ្លួនមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬ **គ.** ប្រសិនបើ [redacted] ស្លាប់ ឬពុំអាចត្រូវបានរកឃើញដោយមានកិច្ចខិតខំយ៉ាងសមស្រប ឯកសារនានាដែលបានកត់ត្រាអំពីលទ្ធផលកិច្ចស៊ើបសួរនេះគួរត្រូវបានដាក់ទៅក្នុងសំណុំរឿង[16]។ ក.ស.ព បានលើកឡើងថាវិធានការសមស្របសម្រាប់ការបំពេញកិច្ចស៊ើបសួរនឹងរួមបញ្ចូល៖ **ក.** ការស្នើសុំព័ត៌មានបន្ថែមពីសាស្ត្រាចារ្យ Kiernan និងសាស្ត្រាចារ្យ Vickery **ខ.** ការទាក់ទងទៅគ្រួសាររបស់ [redacted] និង **គ.** ការណែនាំឲ្យសមត្ថកិច្ចពាក់ព័ន្ធធ្វើការស្រាវជ្រាវរក [redacted][17]។

## II. ច្បាប់ និងទន្និករណ៍

### ក. សំណើរបស់ ក.ស.ព ដោយអនុលោមតាមវិធាន ៩៣ ស្នើសុំបើកកិច្ចស៊ើបសួរគឺជាសំណើពុំទាន់ពេលវេលា

9. សំណើរបស់ ក.ស.ព ដែលស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យមានកិច្ចស៊ើបសួរអំពីទីកន្លែងស្នាក់នៅរបស់ [redacted] ដោយអនុលោមតាមវិធាន ៩៣ គឺជាសំណើពុំទាន់ពេលវេលា និងគួរត្រូវបានបដិសេធ។ ពេលវេលាសមស្របដើម្បីធ្វើសំណើនេះគឺនៅពេលដែល ក.ស.ច.ស បានកំពុងបំពេញកិច្ចស៊ើបសួរតាមផ្លូវតុលាការរបស់ខ្លួន[18]។ តាមការសន្មត ក.ស.ព បានដឹងអំពីអត្ថិភាពរបស់ [redacted] យ៉ាងហោចណាស់ចាប់តាំងពីខែ ធ្នូ ឆ្នាំ ២០០៩ មកម្ល៉េះ គឺនៅពេលដែល ក.ស.ច.ស បានទាក់ទងទៅសាស្ត្រាចារ្យ Kiernan និងបានដាក់ប្រតិចារឹករបស់សាស្ត្រាចារ្យ Kiernan នៃកិច្ចសម្ភាសន៍របស់គាត់ជាមួយ [redacted] ទៅក្នុងសំណុំរឿង។ ជាការពិត ក.ស.ព បានចាត់ទុកថា [redacted] ជាបុគ្គលពាក់ព័ន្ធនឹងសំណុំរឿង ០០២ យ៉ាងហោចណាស់សម្រាប់រយៈពេល ២ ឆ្នាំចុង

[15] *ដូចឯកសារយោងខាងលើ* កថាខណ្ឌ ៧។

[16] *ដូចឯកសារយោងខាងលើ* កថាខណ្ឌ ១៦។

[17] *ដូចឯកសារយោងខាងលើ* កថាខណ្ឌ ១៧។

[18] *សូមមើល* វិធាន ៥៥(១០)។

ក្រោយនេះ ពោលគឺចាប់តាំងពី ក.ស.ព បានដាក់ប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់ [redacted] នៅក្នុងបញ្ជីឯកសាររបស់ខ្លួននៅក្នុងឆ្នាំ ២០១១[19]។ បើទោះបីជាវិធាន ៩៣ ផ្តល់សិទ្ធិអំណាចទៅអង្គជំនុំជម្រះសាលាដំបូងដើម្បីបង្គាប់ *ដោយឯកតោភាគី* ឲ្យមានកិច្ចស៊ើបសួរថ្មីមួយនៅគ្រប់ដំណាក់កាលក៏ដោយ[20] ក៏អង្គជំនុំជម្រះសាលាដំបូងពុំគួរធ្វើដូច្នេះពាក់ព័ន្ធនឹងសំណើនេះឡើយ។

**ខ. ប្រតិចារឹករបស់សាស្ត្រាចារ្យ Kiernan នៃកិច្ចសម្ភាសន៍របស់គាត់ជាមួយ [redacted] គឺពុំអាចឲ្យទទួលយកបានដោយអនុលោមតាមវិធាន ៨៧ ឡើយ**

10. ជនជាប់ចោទមានសិទ្ធិជាសារវ័ន្តក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដើម្បីតទល់ ឬពិនិត្យភស្តុតាង និងសួរដេញដោលសាក្សីដាក់បន្ទុក។ សិទ្ធិនេះត្រូវបានធានាដោយកិច្ចព្រមព្រៀង[21] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[22] វិធាន[23] និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[24] ដែលកម្ពុជាត្រូវតែគោរពដោយអនុលោមតាមរដ្ឋធម្មនុញ្ញកម្ពុជា[25]។ សិទ្ធិរបស់ជនជាប់ចោទដើម្បីតទល់ភស្តុតាង និងសាក្សីដាក់បន្ទុកគឺជា "មូលដ្ឋាននៃសញ្ញាណស៊ីវិល័យ នៃការជំនុំ

---

[19] *សូមមើល* បញ្ជីឯកសារសម្រាប់សវនាការរបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន៨០(៣), ឧបសម្ព័ន្ធ១២៖ ចម្លើយសាក្សី, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១, ឯកសារ E9/31.12, លេខ ៧៩៦។

[20] វិធាន ៩៣(១) ចែងត្រង់ផ្នែកពាក់ព័ន្ធថា៖ "ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាការស៊ើបសួរជាថ្មីជាការចាំបាច់ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឲ្យធ្វើការស៊ើបសួរបន្ថែមបានគ្រប់ពេលវេលា"។

[21] កិច្ចព្រមព្រៀង, មាត្រា ១៣(១)។

[22] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៣៥ ថ្មី(ង)។

[23] វិធាន ៨៤(១)។

[24] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ១៤(៣)(ឃ)។

[25] រដ្ឋធម្មនុញ្ញកម្ពុជា, មាត្រា ៣១។

ជម្រះក្តីដោយយុត្តិធម៌”[26] និងត្រូវបានទទួលស្គាល់ទាំងនៅក្នុងយុត្តាធិការនៃច្បាប់ស៊ីវិល និងច្បាប់ខម៉ិនឡ[27]។

11. នៅ អ.វ.ត.ក ការទទួលយកចម្លើយជាលាយលក្ខណ៍អក្សរ ឬប្រតិចារឹកដែលពាក់ព័ន្ធនឹងសកម្មភាព និងទង្វើរបស់ជនជាប់ចោទពុំត្រូវបានអនុញ្ញាតឡើយ លើកលែងតែមេធាវីការពារក្តីបានទទួលឱកាសដើម្បីតទល់ ឬសួរដេញដោលម្ចាស់ចម្លើយ ឬប្រតិចារឹកនៅក្នុងតុលាការ[28]។ ស្ថិតក្រោមការលើកលែងមួយចំនួនតូច ឯកសារទាំងនេះត្រូវបានចាត់ទុកថា “ពុំត្រូវបានអនុញ្ញាតដោយច្បាប់” ដោយអនុលោមតាមវិធាន ៨៧(៣)(ឃ)[29]។

12. នាពេលក្រោយមកទៀត អង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញអំពីករណីលើកលែងមួយចំពោះវិធាននេះ៖ ចម្លើយជាលាយលក្ខណ៍អក្សរ ឬប្រតិចារឹករបស់សាក្សីដែលស្លាប់ សាក្សីដែលពុំអាចទាក់ទងបានបើទោះបីជាមានកិច្ចខិតខំស្វែងរកយ៉ាងសមស្រប ឬសាក្សីដែលមិនអាចផ្តល់សក្ខីកម្មដោយសារស្ថានភាពផ្លូវកាយឬផ្លូវចិត្ត*អាច*ត្រូវបានទទួលយក សូម្បីតែនៅពេលដែលចម្លើយទាំងនេះទាក់ទងទៅនឹងសកម្មភាព និងទង្វើរបស់ជនជាប់ចោទក៏ដោយ[30]។ អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់អំពីលក្ខខណ្ឌពាចំណុចសម្រាប់ការទទួលយកឯកសារទាំងនេះ៖ **ក.** សាក្សីពិតជាមិនត្រូវបានរកឃើញ **ខ.** ភស្តុតាងត្រូវតែមានភាពជឿជាក់បាន និង **គ.** តម្លៃនៃភស្តុតាងត្រូវ

---

[26] *សំណុំរឿង R. ទល់នឹង Hughes*, 2 N.Z.L.R. 129, 148, *ត្រូវបានដកស្រង់នៅក្នុង* Ian Dennis, *សិទ្ធិតទល់សាក្សី៖ អត្ថន័យ ការប្រឌិត និងសិទ្ធិមនុស្ស*, CRIM. L. R. 255, 255 (2010)។ សិទ្ធិនេះត្រូវបាន “ទទួលស្គាល់យ៉ាងទូលំទូលាយថាជាធាតុផ្សំជាសារវ័ន្តមយនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ ជាជាងដូចជាការសន្មតជាមុនអំពីភាពគ្មានទោស” *ដូចឯកសារយោងខាងលើ* ។

[27] មាត្រា ៦(៣)(ឃ)នៃកតិកាសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្ត ដែលត្រូវបានផ្តល់សច្ចាប័នពីសំណាក់ស្ទើរតែគ្រប់រដ្ឋអឺរ៉ុបទាំងអស់ និងត្រូវបានអនុវត្តនៅក្នុងប្រព័ន្ធគតិយុត្តមួយចំនួន គឺស្រដៀងស្ទើរតែទាំងស្រុងទៅនឹងមាត្រា ១៤(៣)(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[28] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២, ឯកសារ E96/7, កថាខណ្ឌ ២២។

[29] *ដូចឯកសារយោងខាងលើ* ។

[30] *ដូចឯកសារយោងខាងលើ* កថាខណ្ឌ ៣២។

តែពុំមានទំហំធំធេងជាសារវ័ន្ត ដែលធ្វើឲ្យការធានាអំពីការជំនុំជម្រះប្រកបដោយយុត្តិធម៌មិនអាចប្រព្រឹត្តទៅបាន[31]។

13. ពាក់ព័ន្ធនឹងការបញ្ជាក់អំពីភាពអាចជឿជាក់បាននៃភស្តុតាងដែលភាគីបានស្នើសុំបង្ហាញ កត្តាខាងក្រោមនេះត្រូវបានចាត់ទុកថាជាកត្តាពាក់ព័ន្ធ ដែលត្រូវបានកំណត់នៅក្នុងយុត្តិសាស្ត្រនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី៖

**ក.** កាលៈទេសៈដែលចម្លើយត្រូវបានធ្វើ និងកត់ត្រា រួមទាំងថាតើចម្លើយនេះត្រូវបានធ្វើឡើងដោយមានការធ្វើសម្បថ ថាតើចម្លើយនេះត្រូវបានចុះហត្ថលេខាដោយសាក្សីដោយមានការទទួលស្គាល់អមមកជាមួយថាចម្លើយនេះពិតជាចម្លើយពិតប្រាកដ តាមការចងចាំល្អបំផុតរបស់គាត់ និងថាតើចម្លើយនេះត្រូវបានធ្វើឡើងដោយមានជំនួយពីមន្ត្រីបកប្រែផ្ទាល់មាត់ដែលមានគុណវុឌ្ឍិត្រឹមត្រូវដែរ ឬយ៉ាងណា

**ខ.** ថាតើចម្លើយនេះបានឆ្លងកាត់ការសួរដេញដោលដែរ ឬយ៉ាងណា

**គ.** ថាតើចម្លើយនេះទាក់ទងនឹងហេតុការណ៍នានាដែលមានភស្តុតាងផ្សេងៗអំពីហេតុការណ៍ទាំងនោះដែរ ឬយ៉ាងណា និង

**ឃ.** កត្តាផ្សេងៗ ដូចជាការគ្មានចំណុចពុំស៊ីសង្វាក់ជាក់ស្តែង ឬច្បាស់លាស់នៅក្នុងចម្លើយទាំងនេះ[32]

14. ផ្ទុយទៅនឹងការលើកឡើងរបស់ ក.ស.ព[33] ប្រសិនបើ [redacted] ស្លាប់ ឬពុំអាចរកឃើញ បើទោះបីជាមានកិច្ចខិតខំស្វែងរកសមស្រប ប្រតិចារឹកសរសេរដោយដៃរបស់សាស្ត្រាចារ្យ Kiernan នៃកិច្ចសម្ភាសន៍របស់គាត់ជាមួយ [redacted] នឹង*ពុំ*អាចឲ្យទទួលយកបានជំនួសឲ្យសក្ខីកម្មរបស់ [redacted] នៅ

[31] *ដូចឯកសារយោងខាងលើ* ។

[32] *ដូចឯកសារយោងខាងលើ* កថាខណ្ឌ៣២, ជើងទំព័រ ៥៤, *ដោយលើកឡើងអំពីសំណុំរឿង រដ្ឋអាជ្ញា ទល់នឹង* Tolimir, លេខសំណុំរឿង IT-05-88/2-PT, សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាស្នើសុំការទទួលយកភស្តុតាងដោយអនុលោមតាមវិធាន ៩២ *ស្ទួនប៊ី* ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩, កថាខណ្ឌ ២៩។

[33] សំណើ, កថាខណ្ឌ ៧,១១។

ក្នុងសវនាការឡើយ។ ពុំមានភស្តុតាងគ្រប់គ្រាន់ដែលថាប្រតិចារឹកនេះអាចឲ្យជឿជាក់បានឡើយ។ ហេតុដូច្នេះ ប្រតិចារឹកនេះពុំត្រូវបានអនុញ្ញាត ដោយអនុលោមតាមច្បាប់ ហើយការទទួលយកប្រតិចារឹកនេះជាភស្តុតាងនឹងរំលោភវិធាន ៨៧[34]។

15. ពុំមានព័ត៌មានគ្រប់គ្រាន់អំពីកាលៈទេសៈជុំវិញកិច្ចសម្ភាសន៍របស់ [redacted] ជាមួយសាស្ត្រាចារ្យ Kiernan និងការបង្កើតប្រតិចារឹកនេះឡើយ។ ព័ត៌មានតែមួយគត់ដែលអង្គជំនុំជម្រះសាលាដំបូង និងភាគីមានគឺការបញ្ជាក់របស់សាស្ត្រាចារ្យ Kiernan ដែលថាកិច្ចសម្ភាសន៍របស់គាត់ជាមួយ [redacted] ត្រូវបានថតខ្សែអាត់ ហើយការយោងរបស់គាត់ទៅលើឯកសារនេះ គឺជាការបកប្រែដែលសរសេរដោយដៃនៃកិច្ចសម្ភាសន៍នេះ[35]។ ខ្សែអាត់នៃកិច្ចសម្ភាសន៍នេះពុំត្រូវបានរកឃើញឡើយ។ ហេតុដូច្នេះ ខ្លឹមសារនៃប្រតិចារឹកនេះពុំអាចត្រូវបានផ្ទៀងផ្ទាត់ដោយត្រឹមត្រូវឡើយ។ ពុំមានភស្តុតាងដែលថា [redacted] បានធ្វើសម្បថនៅមុនពេលគាត់ផ្តល់បទសម្ភាសន៍ឡើយ ហើយក៏គ្មានភស្តុតាងណាមួយដែលថា [redacted] ធ្លាប់បានឃើញប្រតិចារឹកនេះឡើយ កុំថាឡើយដល់គាត់បានបញ្ជាក់អំពីភាពត្រឹមត្រូវនៃប្រតិចារឹកនេះ។ ប្រតិចារឹកនេះពុំត្រូវបានចុះហត្ថលេខាដោយ [redacted] ឬសាស្ត្រាចារ្យ Kiernan ឡើយ។ ពុំមានភស្តុតាងថាតើអ្នកណាបានដើរតួនាទីជាអ្នកបកប្រែក្នុងអំឡុងកិច្ចសម្ភាសន៍នេះ ឬគុណវុឌ្ឍិរបស់បុគ្គលនេះក្នុងនាមជាអ្នកបកប្រែ។ លើសពីនេះទៀត ថ្វីបើកាលបរិច្ឆេទជាក់លាក់នៃកិច្ចសម្ភាសន៍ត្រូវបានដាក់បញ្ចូលនៅក្នុងប្រតិចារឹកក៏ដោយ ក៏ពុំមានព័ត៌មានថាតើសាស្ត្រាចារ្យ Kiernan បានបង្កើតប្រតិចារឹកនេះនៅថ្ងៃតែមួយជាមួយកិច្ចសម្ភាសន៍ ឬនៅពេលក្រោយមកទៀតឬ យ៉ាងណា។

16. អ្នកសរសេរប្រតិចារឹកនេះនឹងពុំស្ថិតក្រោមការតទល់ ឬការសួរដេញដោលពីសំណាក់អង្គជំនុំជម្រះសាលាដំបូង ឬភាគីឡើយ។ សាស្ត្រាចារ្យ Kiernan នឹងពុំបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដើម្បីផ្តល់ភស្តុតាងឡើយ[36]។ ហេតុដូច្នេះ ទាំងអង្គជំនុំជម្រះសាលាដំបូង និងភាគីនឹង

---

[34] *សូមមើល* វិធាន ៨៧(៣)(ឃ)។

[35] *សូមមើល* ចម្លើយតបរបស់ Ben Kiernan ទៅ ស.ច.ស ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១០, ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០, ឯកសារ D269/4, កថាខណ្ឌ ៦។

[36] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "សក្ខីកម្មរបស់ Benedict KIERNAN ដែលភាគីបានស្នើសុំនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង", ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២, ឯកសារ E166/1/4។

ពុំមានឱកាសដើម្បីសួរដេញដោលសាស្ត្រាចារ្យ Kiernan អំពីកាលៈទេសៈជុំវិញកិច្ចសម្ភាសន៍របស់ [redacted] និងការបង្កើតប្រតិចារឹកនេះឡើយ។

17. ប្រតិចារឹកនេះគឺជាឯកសារដែលសរសេរដោយដៃក្រៅផ្លូវការ ដែលត្រូវបានគេជឿថាសាស្ត្រាចារ្យ Kiernan បានបង្កើតឡើង។ ប្រតិចារឹកនេះ*ពុំមែន*ជាចម្លើយសាក្សីមួយដែលត្រូវបានចុះហត្ថលេខាដោយ [redacted] ឬជាប្រតិចារឹក អ.វ.ត.ក ជាផ្លូវការនៃសក្ខីកម្មរបស់ [redacted] នៅក្នុងសវនាការកាលពីពេលកន្លងមកឡើយ។ ប្រតិចារឹកនេះពុំមាន*សញ្ញាបង្ហាញ* ឯករាជ្យគ្រប់គ្រាន់អំពីភាពអាចជឿជាក់បានដែលនឹងអនុញ្ញាតឱ្យទទួលយកជាភស្តុតាង ដោយអនុលោមតាមវិធាន ៨៧ ឡើយ។ អង្គជំនុំជម្រះសាលាដំបូងពុំគួរទទួលយកឯកសារនេះ ជំនួសឱ្យសក្ខីកម្មរបស់ [redacted] នៅក្នុងសវនាការឡើយ។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងសម្រេចថាប្រតិចារឹករបស់សាស្ត្រាចារ្យ Kiernan មានភាពអាចជឿជាក់បាន និងទទួលយកវាជាភស្តុតាងក៏ដោយ ក៏ប្រតិចារឹកនេះត្រូវបាន បានទទួលតម្លៃជាភស្តុតាងតិចតួចប៉ុណ្ណោះ ប្រសិនបើមាន[37]។

**អាស្រ័យហេតុនេះ** តាមសំអាងហេតុដូចដែលបានបញ្ជាក់ខាងលើ មេធាវីការពារក្តីសូមគោរពស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង **បដិសេធ** សំណើរបស់ ក.ស.ព ដែលស្នើសុំទទួលយកប្រតិចារឹករបស់សាស្ត្រាចារ្យ Kiernan នៃកិច្ចសម្ភាសន៍របស់គាត់ជាមួយ [redacted] ជំនួសឱ្យសក្ខីកម្មនៅក្នុងសវនាការ នៅក្នុងករណីដែលមានការសម្រេចថា [redacted] ស្លាប់ ឬពុំអាចត្រូវបានស្វែងរកឃើញបើទោះបីជាមានកិច្ចខិតខំស្វែងរកដ៏សមស្របក៏ដោយ។

សូមអង្គជំនុំជម្រះទទួលនូវក្តីគោរពអំពីយើងខ្ញុំ។

| | |
|---|---|
| អាង ឧត្តម | Michael G. KARNAVAS |

សហមេធាវីរបស់លោក អៀង សារី

ចុះហត្ថលេខានៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី **៤** ខែ **មីនា ឆ្នាំ ២០១៣**

[37] *ដូចឯកសារយោងខាងលើ* ទំព័រ ២៖ "អនុលោមតាមគោលការណ៍នៃការធានាឱ្យមានការជំនុំជម្រះដោយយុត្តិធម៌ ដែលជាគោលការណ៍អន្តរជាតិនោះ ដោយហេតុថាអង្គជំនុំជម្រះសាលាដំបូងពុំមានលទ្ធភាពកោះហៅសាស្ត្រាចារ្យ Kiernan ទើបសេចក្តីសន្និដ្ឋាននានារបស់គាត់អាចមានតម្លៃភស្តុតាងតិចតួច ប្រសិនបើមាន នៅក្នុងសំណុំរឿង ០០២ ដោយហេតុថាភាគីពុំអាចលើកការជំទាស់ណាមួយតទល់ជាមួយគាត់បាន"។